ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ អង្គប្រជុំដឹកនាំដោយឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** បានសំដែងអំណរសាទរដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឱ្យខិតខំជំនះការលំបាក និងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឱ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានល្អប្រសើរផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានាសំដៅធ្វើឱ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤។



ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ២៩៩ ៤១៧ លានរៀល (គិតជាដុល្លារ ៧៤,៨៥ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤ នេះមានការកើនឡើងស្មើនឹង ៣៥,១៥%។

ក្នុងរយៈពេលដប់មួយខែនៃឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធដារនិងបង់ចូលថវិកាជាតិ បានចំនួនស្មើនឹង **៩៦,៦១%** នៃគោលដៅកំណត់ដោយច្បាប់ ក្នុងនោះថវិការដ្ឋសម្រេចបានចំនួនស្មើនឹង ៩៧,០៥% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានចំនួនស្មើនឹង ៩៣,៧៧%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារចូលថវិកាជាតិសម្រាប់ឆ្នាំ២០១៤នេះ មានការកើនឡើងចំនួនស្មើនឹង **២០,០៩%**។

ប្រសិនបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលតាមប្រភេទពន្ធសំខាន់ៗ មានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន÷ ពន្ធលើប្រាក់បៀវត្សកើនឡើងចំនួនស្មើនឹង ៣១,៩% ពន្ធលើប្រាក់ចំណេញកើនឡើងចំនួនស្មើនឹង ២៥,៨% អាករលើតម្លៃបន្ថែមកើនឡើងចំនួនស្មើនឹង ១៤,៧% និងអាករពិសេសកើនឡើងចំនួនស្មើនឹង ១៣,៣%។

បើប្រៀបធៀបទៅនឹងរយៈពេល១១ខែ ដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលពន្ធតាមសកម្មភាពអាជីវកម្ម មានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ១៧,៧% សេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២២,៧% ទូរគមនាគមន៍កើនឡើងប្រមាណ ២,៩% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៥៤,២% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣៣,៤% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៤៧,៩% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ១៣,១% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤៥,៤% ផលិតថ្នាំជក់កើនឡើងប្រមាណ ១២,០% អាជីវកម្មអចលនទ្រព្យកើនឡើងប្រមាណ ១៣៨,៥% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ១៥,៧% លក់ភេសជ្ជៈកើនឡើងប្រមាណ ៣២,៩% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៣៨,២% ផលិតម្ហូបអាហារកើនឡើងប្រមាណ ៧៦,១% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៤២,៧% លក់ផលិតផលឱសថកើនឡើងប្រមាណ ១៥៦,៩% និងលក់គ្រឿងសំណង់កើនឡើងប្រមាណ ១.៣២២,៤%។



ក្នុងការពិភាក្សាអង្គប្រជុំបានផ្ដោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-ពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែរបស់នាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ។ II-វឌ្ឍនភាពនៃការចាត់អាជីវកម្មដ្ឋានជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស វិធានការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ និងការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤។ III-ពង្រឹងការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មី និងការធ្វើបច្ចុប្បន្នភាពសហគ្រាស។ IV-វឌ្ឍនភាពការងារផ្នែកតាមផែនការសកម្មភាពដោះស្រាយបញ្ហាជាក់ស្ដែងរបស់អគ្គនាយកដ្ឋានពន្ធដារ V-បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឲ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈនោះ ជាទិសដៅអនុវត្តបន្ត អគ្គនាយកដ្ឋានពន្ធដារនឹងត្រូវយកយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ យកធ្វើជាត្រីវិស័យបង្ហាញផ្លូវក្នុងការប្រមូលចំណូលសម្រាប់រយៈពេលមួយខែចុងក្រោយនៃឆ្នាំ២០១៤ ក៏ដូចជាសម្រាប់បណ្ដាឆ្នាំខាងមុខ។

ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្ដល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌ វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរតាមរយៈការផ្ដល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត។

**អគ្គនាយកដ្ឋានពន្ធដារ**